## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីសម្រេចបន្តអាណត្តិអាជ្ញាប័ណ្ណរួមលេខ ០៤៩ ឯអ
## សម្រាប់លោកស្រី ខៀវ ណារ៉េត
## អាជ្ញាធរអគ្គិសនីកម្ពុជា

-អនុវត្តតាមមាត្រា ៧ និង ៣៥ របស់ច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១

-យោងឯកសារអាជ្ញាប័ណ្ណលេខ០៤៩ឯអ ដែលអាជ្ញាធរអគ្គិសនីកម្ពុជាបានចេញឱ្យលោកស្រី ខៀវ ណារ៉េត នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣

-យោងពាក្យស្នើសុំបន្តអាណត្តិអាជ្ញាប័ណ្ណរបស់លោកស្រី ខៀវ ណារ៉េត ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៥

-យោងតាមការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ និងសាធារណជន ដែលបានធ្វើចាប់ពីថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០០៥ ដល់ថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០០៥

-យោងតាមការអនុម័តរបស់សម័យប្រជុំ **អាជ្ញាធរអគ្គិសនីកម្ពុជា** លើកទី៥៤ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥

## សម្រេច

**ប្រការ១**

ដោយលោកស្រី ខៀវ ណារ៉េត បានធ្វើការកែលំអមធ្យោបាយធ្វើសេវាកម្ម អគ្គិសនីរបស់ខ្លួនបានមួយភាគធំ ហើយត្រូវធ្វើការកែលំអច្រើនបន្តទៀតនៅឆ្នាំបន្ត បន្ទាប់ដើម្បីឱ្យសមស្របតាមល័ក្ខខ័ណ្ឌទូទៅ នៃស្តង់ដាបច្ចេកទេសអគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា អាជ្ញាធរអគ្គិសនីកម្ពុជាសម្រេចកែសម្រួលអាជ្ញាប័ណ្ណរួម លេខ ០៤៩ ឯអ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ ដែលបានផ្តល់ជូន លោកស្រី ខៀវ ណារ៉េត ដោយបន្តអាណត្តិអាជ្ញាប័ណ្ណចំនួន ៤ឆ្នាំ ទៀត។

**ប្រការ២**

អាណត្តិថ្មីរបស់អាជ្ញាប័ណ្ណនេះ មានរយៈពេល ៤ឆ្នាំ គិតចាប់ពីថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៥ និងអាចស្នើសុំបន្តទៀត ឬស្នើសុំកែសម្រួល លើកលែងតែត្រូវដកហូត ដោយអនុលោមតាមល័ក្ខខ័ណ្ឌនៃអាជ្ញាប័ណ្ណនេះ។

**ប្រការ៣**

សេចក្តីសម្រេចនេះ ត្រូវក្លាយជាផ្នែកមួយនៃអាជ្ញាប័ណ្ណលេខ ០៤៩ ឯអ ។

**ប្រការ៤**

ខ្លឹមសារ និងល័ក្ខខ័ណ្ឌដទៃទៀតនៃឯកសារអាជ្ញាប័ណ្ណលេខ ០៤៩ឯអ ត្រូវស្ថិតនៅជាធរមានដដែល ។

**ប្រការ៥**

សេចក្តីសម្រេចនេះ ត្រូវចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ប្រការ៦**

អ្នកកាន់អាជ្ញាប័ណ្ណ ត្រូវផ្ញើរសេចក្តីសម្រេចនេះ ទៅតំកល់ទុកបន្ថែមនៅ តាមទីកន្លែងដែលឯកសារអាជ្ញាប័ណ្ណលេខ ០៤៩ឯអ ដែលបានតម្កល់ទុកពីមុន ដើម្បីឱ្យឯកសារអាជ្ញាប័ណ្ណលេខ ០៤៩ឯអ ដែលតម្កល់ទុកមានការកែសម្រួលជាថ្មី ស្របតាមសេចក្តីសម្រេចនេះ ។

ភ្នំពេញ, ថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៥

**ប្រធានអាជ្ញាធរអគ្គិសនីកម្ពុជា**

# ឧបសម្ព័ន្ធទី២

## មធ្យោបាយផលិតកម្មដែលមានស្រាប់របស់អ្នកកាន់អាជ្ញាប័ណ្ណ

### ក-មធ្យោបាយផលិតកម្មរបស់អ្នកកាន់អាជ្ញាប័ណ្ណ

**រោងម៉ាស៊ីន**

១- រោងម៉ាស៊ីនរបស់អ្នកកាន់អាជ្ញាប័ណ្ណ ស្ថិតក្នុងភូមិព្រែកបាន ឃុំត្រើយស្លា ស្រុកស្អាង ខេត្តកណ្តាល ។

**លក្ខណៈទូទៅនៃម៉ាស៊ីន**

១- អ្នកកាន់អាជ្ញាប័ណ្ណ មានម៉ាស៊ីនភ្លើងចំនួន ០៤គ្រឿង ដែលមានអានុភាព តំឡើងសរុប 415kVA គឺ:

-ម៉ាស៊ីនទី១ : អានុភាពដើម 150kVA

-ម៉ាស៊ីនទី២ : អានុភាពដើម 50kVA

-ម៉ាស៊ីនទី៣ : អានុភាពដើម 30kVA

-ម៉ាស៊ីនទី៤ : អានុភាពដើម 185kVA

២- ម៉ាស៊ីនភ្លើងខាងលើ ប្រើប្រាស់ប្រេងម៉ាស៊ូត ។

លក្ខខ័ណ្ឌរបស់អាជ្ញាប័ណ្ណនេះមានខ្លឹមសារដូចអាជ្ញាប័ណ្ណលេខ០១៥.ឯអ ចុះថ្ងៃទី២២ ខែវិច្ឆិការ ឆ្នាំ២០០២។
ប្រសិនបើចង់ពិនិត្យមើលខ្លឹមសារ សូមពិនិត្យមើលផ្នែកទី២ របស់អាជ្ញាប័ណ្ណនេះ ។